ប្រការ ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ អភិបាលគ្រប់ខេត្ត ក្រុង និង អស់អ្នកដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ច រៀង ៗ ខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

សហប្រធាន

រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

ព្រះហស្តលេខា ហត្ថលេខា

សម្តេចក្រុមហ្លួន នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * * *

ភ្នំពេញ, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៩៣

## សេចក្តីសំរេច លេខ២៤ សសរ

## រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

* * *

- បានឃើញក្រឹត្យ ស្តីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា របស់ សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ប្រមុខរដ្ឋនៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣
- យោងតាមសំណើរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ លេខ ៣៩៧៥ ការបទ អមរ ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៣

## សំរេច

ប្រការ ១ : បង្កើតគណៈកម្មាធិការសៅរ៉ាយការណ៍ជាតិស្តីពីសិទ្ធិមនុស្ស

MIA/POW នៅកម្ពុជា ដែលមានសមាសភាពដូចតទៅ ៖

១- ឯកឧត្តមសហអនុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ សហប្រធាន

២- ឯកឧត្តមអនុរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៣- តំណាងក្រសួងការពារជាតិ សមាជិក

៤- ឯកឧត្តម អភិបាល ខេត្ត ក្រុង សមាជិក

៥- លោកវេជ្ជបណ្ឌិតតំណាងក្រសួងសុខាភិបាល សមាជិក

៦- នាយកដ្ឋានតំរួតព្រហ្មទណ្ឌសេដ្ឋកិច្ច ក្រសួងមហាផ្ទៃ និងសន្តិសុខជាតិ សមាជិក

៧- នាយកដ្ឋានអាមេរិក ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ សមាជិក

ប្រការ ២ : គណៈកម្មាធិការ MIA/POW មានភារកិច្ចស្រាវជ្រាវរុករកអដ្ឋិធាតុអាមេរិក ដោយសហការជាមួយរដ្ឋអំណាចមូលដ្ឋាន ខេត្ត ក្រុង ដែលមានការពាក់ព័ន្ធ និង ត្រៀម ទទួលធ្វើការជាមួយគណៈប្រតិភូជំនាញអាមេរិក អំពីការស្រាវជ្រាវរុករក អដ្ឋិធាតុ ទាហានអាមេរិកបាត់ខ្លួន នៅប្រទេសកម្ពុជា ។

ប្រការ ៣ : គណៈកម្មាធិការមានសិទ្ធិប្រើប្រាស់ត្រាជាផ្លូវការរបស់ក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ និង ប្រើប្រាស់រថយន្តដែលភាគីអាមេរិកបានផ្តល់ជូនមក ជាមធ្យោបាយធ្វើ ដំណើរ ។

ប្រការ ៤ : សមាជិកទាំងអស់ ត្រូវចូលរួមប្រជុំ និង ធ្វើការងារតាមការអញ្ជើញរបស់ ឯកឧត្តម ប្រធានគណៈកម្មាធិការ ។

ប្រការ ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងសន្តិសុខជាតិ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល អភិបាលខេត្ត ក្រុង និងសាមីខ្លួន ដែលមាន ក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ។

**សហប្រធាន**

**រដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា**

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

ស្តេចក្រុមហ្លួង **នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**